


# 2026-2027
# គោលការណ៍ណែនាំសំរាប់ការត្រឡប់ចូលរៀនវិញ

LONG BEACH
UNIFIED • SCHOOL • DISTRICT

**សាលាភាគច្រើនចាប់ផ្តើមទទួលសិស្សចូលរៀននៅថ្ងៃទី25 ខែសីហា**

**CAMS និង Sato ចាប់ផ្តើមទទួលសិស្សចូលរៀននៅថ្ងៃទី12 ខែសីហា**

សូមទាក់ទងសាលានៃសិស្សរបស់អ្នក និងបើកមើលនៅតាម lbschools.net/back2schools ដើម្បីទទួលបាននូវព័ត៌មានបន្ថែម

# ដើម្បីទៅដល់ទីនោះ យើងត្រូវធ្វើដំណើររួមគ្នា!

ជំរាបជូនមាតាបិតា អ្នកមើលថែ និងអាណាព្យាបាលជាទីរាប់អាន

សូមស្វាគមន៍មកកាន់មន្ទីរអប់រំ ឡុងប៊ីច និងឆ្នាំសិក្សា 2026-2027! ខណៈពេលដែលយើងចាប់ផ្តើមឆ្នាំសិក្សាថ្មីដែលពោរពេញដោយការសិក្សា ភាពលូតលាស់ និងឱកាសដ៏ល្អៗ គឺខ្ញុំសូមថ្លែងអំណរគុណចំពោះជំនឿដែលអ្នកផ្តល់មកកាន់មន្ទីរអប់រំ ឡុងប៊ីច។ គោលការណ៍ណែនាំសំរាប់ការត្រឡប់ចូលរៀនវិញនេះ ត្រូវបានរៀបចំឡើង ដើម្បីជួយសិស្ស និងក្រុមគ្រួសារចាប់ផ្តើមឆ្នាំសិក្សា ស្របដោយទំនុកចិត្ត ដោយមានការលើកផ្តល់ជាព័ត៌មាន ធនធាន និងមធ្យោបាយសំខាន់ៗជាច្រើនក្នុងការគាំទ្រឆ្នាំសិក្សាឱ្យបានប្រកបដោគជ័យ។

ខ្ញុំចង់បានឱ្យសិស្ស ក្រុមគ្រួសារ បុគ្គលិក និងសមាជិកសហគមន៍ទាំងអស់មានការដឹងឮថា៖ **អ្នកមានការទទួលស្វាគមន៍នៅទីនេះ**។ ខ្ញុំធ្វើការតាំងប្តេជ្ញាចិត្ត ដើម្បីស្តាប់ រៀន និងធ្វើកិច្ចការជាមួយសហគមន៍មន្ទីរអប់រំ ឡុងប៊ីច ទាំងមូលរបស់យើង។ យើងនឹងនៅតែធ្វើការបន្តជាដដែល ដើម្បីពង្រីកឱកាសសំរាប់សិស្សគ្រប់រូប ដោយមូលហេតុថា ដើម្បីទៅដល់ទីនោះ យើងត្រូវធ្វើដំណើរ**រួមគ្នា**។

ដោយសាមគ្គីភាព

David Zaid

អគ្គនាយក



**សូមធ្វើការទាក់ទងយើងខ្ញុំ**

គេហទំព័រមន្ទីរអប់រំ - lbschools.net

គេហទំព័រសាលា -
ឈ្មោះសាលា.lbschools.net

*ឧទាហរណ៍*

avalon.lbschools.net
los-cerrtios.lbschools.net

សំណួរអំពីកម្មវិធីអប់រំនៅតាមកំរិតថ្នាក់ផ្សេងៗ

កម្មវិធីអប់រំសំរាប់កុមារវ័យខ្ចី
lbschools.net/earlylearning

ការិយាល័យកំរិតថ្នាក់បឋមសិក្សា
(562) 997-8247

ការិយាល័យកំរិតថ្នាក់មធ្យមសិក្សា
K-8 និង អនុវិទ្យាល័យ
(562) 997-8100

វិទ្យាល័យ
(562) 997-8115

## peachjar សំរាប់ក្រុមគ្រួសាររបស់មន្ទីរអប់រំ LBUSD

ក្នុងមួយចំណែកនៃការប្រឹងប្រែងរបស់យើង ដើម្បីថែរក្សាបរិស្ថានកាន់តែជិតដល់ គឺមន្ទីរអប់រំ LBUSD បានធ្វើការកែប្រែពីការប្រើក្រដាសអំពីការចុះផ្សាយព័ត៌មានក្នុងខិតប័ណ្ណឱ្យទៅជារបៀបអេឡិចត្រូនិចវិញតាមរយៈ Peachjar។ ខិត្តប័ណ្ណចុះផ្សាយពីមន្ទីរអប់រំ LBUSD ឬក្រសួងមិនយកកំរៃ និងក្រសួងរដ្ឋាភិបាលផ្សេងៗ ដែលត្រូវបានទទួរការអនុម័ត គឺនឹងផ្ញើជូនអ្នកផ្ទាល់ ដោយដាក់នៅក្នុងប្រអប់ អ៊ីម៉េល របស់អ្នក និងតាំងបង្ហាញនៅក្នុងគេហទំព័រសាលា។ ក្រុមគ្រួសារអាចអានពិនិត្យបានអំពីព័ត៌មាននៅក្នុងខិតប័ណ្ណនាពេលបច្ចុប្បន្ន ដែលចុះផ្សាយកម្មវិធី និងព្រឹត្តិការណ៍ផ្សេងៗនាពេលអានាគត ដោយចុចលើគន្លិះ Peachjar នៅតាមគេហទំព័រសាលារបស់ពួកគេរៀងៗខ្លួន។

lbschools.net/peachjar

## ធ្វើទំនាក់ទំនងជាមួយគ្នា

ធ្វើការតាមដាន
យើងខ្ញុំតាមរយៈ
ប្រព័ន្ធដូចតទៅ៖

@LongBeachUSD



រៀនចំណាំទុកអំពីព្រឹត្តិការណ៍របស់មន្ទីរអប់រំ នៅតាម៖

**lbschools.net/calendar**



# បញ្ជីត្រួតពិនិត្យសំរាប់ ការត្រឡប់ចូលរៀនវិញ

**ពិនិត្យមើលនៅតាម lbschools.net និងគេហទំព័រសាលា** ដើម្បីទទួលបាននូវព័ត៌មានថ្មីៗ។

**ធ្វើការបញ្ជាក់ថា ព័ត៌មានសំរាប់ងាយទាក់ទងអ្នក គឺមានភាពច្បាស់លាស់នៅក្នុង ParentVue នាពេលបច្ចុប្បន្ន**

គេហទំព័រនេះ lbschools.net/parentVue ផ្តល់សិទ្ធិសំរាប់អ្នកពិនិត្យមើលសំណុំរឿងសិក្សានៃកូនរបស់អ្នកក្នុងពេលបច្ចុប្បន្ន និងពីពេលកន្លងមក ដូចជា៖ វត្តមានសិក្សា និងលេខពិន្ទុសិក្សា ជាដើម។ បើអ្នកមិនបានទទួលព័ត៌មាននៅតាមអ៊ីម៉េល ថិច្ច ឬទូរស័ព្ទ ឬបើអ្នកត្រូវការជំនួយសំរាប់ការចុះឈ្មោះ គឺសូមទាក់ទងសាលានៃសិស្សរបស់អ្នក។



**បំពេញព័ត៌មានថ្មីៗប្រចាំឆ្នាំអំពីគ្រួសាររបស់អ្នកតាមរយៈ អនឡាញ**

ក្រុមគ្រួសារគួរតែធ្វើការបញ្ជាក់ថា គេបានទទួលព័ត៌មាន និងបានធ្វើការកែតម្រូវហើយចំពោះព័ត៌មានសំខាន់ៗអំពីគ្រួសាររបស់ពួកគេរៀងៗខ្លួននៅក្នុង **ParentVue** ដោយចុះឈ្មោះធ្វើការបញ្ជាក់នៅតាមគេហទំព័រ **lbschools.net/parentvue**។

**ធ្វើការបញ្ជាក់ឱ្យដឹងអំពីពេលវេលា ដែលសិស្សរបស់អ្នកចាប់ផ្តើមចូលរៀន**

នៅតាមវិទ្យាល័យ គឺសិស្សចាប់ផ្តើមចូលរៀននៅម៉ោង 8:45 ព្រឹក និងនៅតាមអនុវិទ្យាល័យ គឺសិស្សចាប់ផ្តើមចូលរៀននៅម៉ោង 8:00 ព្រឹក ក្នុងរដូវស្លឹកឈើធ្លាក់ឆ្នាំនេះ។ សូមអានព័ត៌មានបន្ថែមនៅក្នុងគេហទំព័រសាលានៃសិស្សរបស់អ្នក ដើម្បីយល់ដឹងកាន់តែច្បាស់។

**នាំសមាជិកនៃគ្រួសារទាំងអស់របស់អ្នកទៅទទួលការចាក់ថ្នាំការពារជំងឺចាំបាច់**

ក្រសួងសុខាភិបាលបានធ្វើការសម្រេចមកថា ការចាក់ថ្នាំការពារជំងឺ គឺមានសុវត្ថិភាព និងប្រសិទ្ធិភាព។ ការចាក់ថ្នាំ គឺសំខាន់ ដើម្បីការពារសុខភាពរបស់អ្នក និងសុខភាពរបស់អ្នកដទៃ។ សូមរៀនបន្ថែមអំពីក្រសួងសុខាភិបាល ដោយបើកមើលនៅក្នុងគេហទំព័រ៖ **longbeach.gov/health**។



**សូមប្រុងប្រយ័ត្នអំពីសកម្មភាពនៃកូនរបស់អ្នកនៅក្នុងប្រព័ន្ធផ្សព្វផ្សាយសង្គម**

សូមមេត្តាចងចាំថា ចំពោះសិស្សណា ដែលបង្ហាញការប្រើអំពើគំរាមកំហែង សូម្បីគ្រាន់តែជាការលេងសើចកំប្លែងក៏ដោយ គឺអាចជាប់ការចាប់ខ្លួនបាន និងទទួលទោសយ៉ាងធ្ងន់ ដែលមានរួមទាំងការបណ្តេញចេញពីសាលាផង។ បើអ្នក ឬកូនរបស់អ្នកបានឃើញ ឬស្តាប់ឮអំពីហេតុការណ៍អ្វី ដែលគួរឱ្យសង្ស័យ គឺសូមមេត្តានិយាយបង្ហាញ។

**ហាត់ប្រើតាមទំលាប់ថ្មី**

ទំលាប់ប្រចាំថ្ងៃ ដូចជា៖ ភ្ញាក់ឡើង និងស្លៀកពាក់ទាន់ពេលវេលា ទទួលអាហារទាន់ពេលវេលា និងរៀននៅសុំាក្បែរមនុស្សធំ និងសិស្សផ្សេងៗដូចគ្នា គឺសំខាន់ណាស់ក្នុងការងាយបែរត្រឡប់ចូលសាលាវិញ។

**lbschools.net/back2school**

# ការប្តេជ្ញាចិត្តរបស់យើងមកលើសុវត្ថិភាព

## សុវត្ថិភាព និង ភាពសន្តិសុខ

សាលាទាំងអស់របស់យើង គឺមានការមើលថែដោយការិយាល័យរក្សាសុវត្ថិភាពប្រចាំមន្ទីរអប់រំ LBUSD ដែលរៀបចំផែនការសើរើមើល និងកែតម្រូវ ដោយប្រើតាមគោលការណ៍របស់ក្រសួងប្រចាំតំបន់ ថ្នាក់រដ្ឋ និងថ្នាក់ជាតិ។ មន្ទីរអប់រំ LBUSD ក៏នឹងប្រព្រឹត្តតាមដែរមកលើប្រព័ន្ធធ្វើសេចក្តីរាយការណ៍តាមការនិយាយបង្ហាញ ដើម្បីធ្វើការបញ្ជាក់ថា សុវត្ថិភាព គឺជាមុខងារទទួលខុសត្រូវរបស់យើងគ្រប់គ្នានៅក្នុងសហគមន៍។ សូមរៀនបន្ថែម ដោយបើកមើលនៅតាម៖ **lbschools.net/safety**។

## សេចក្តីរំលឹកអំពីចរាចរណ៍ និងអ្នកថ្មើរជើង

ចំនួនអ្នកថ្មើរជើង និងចរាចរណ៍បើកបរ នឹងមានកាន់តែច្រើនឡើងនៅជុំវិញសាលាបន្ទាប់ពីសិស្សចាប់ផ្តើមចូលរៀនវិញ។ សូមមេត្តាចងចាំទុកអំពី៖




- ការធ្វើទាំងប្រយ័ត្នប្រយែងកាន់តែច្រើន
- ឈប់ ដើម្បីឱ្យអ្នកថ្មើរជើងឆ្លងផ្លូវផុតសិន
- ជៀសវាងការរំខាន នៅពេលកំពុងតែបើកបរ
- ប្រយ័ត្ន និងគោរពតាមបញ្ជារបស់អ្នកចម្លងផ្លូវ
- គោរពតាមវិន័យ នៅពេលទម្លាក់សិស្សចុះ
- បង្ហាត់សិស្សរបស់អ្នកឱ្យឆ្លងផ្លូវ ដោយរង់ចាំនៅតាមកាច់ជ្រុងផ្លូវ។

## ការឈរួមគ្នា៖ ការបង្កើនសមត្ថភាពសំរាប់សិស្ស និងក្រុមគ្រួសារជាជនអន្តោប្រវេសន៍

នៅមន្ទីរអប់រំ ឡុងប៊ិច គឺយើងមានការតាំងប្តេជ្ញាចិត្ត ដើម្បីបញ្ជាក់ថា សិស្សគ្រប់រូបមានសុវត្ថិភាព ទទួលការផ្តល់តម្លៃមកលើ និងការគាំទ្រ ជាពិសេស សិស្ស និងក្រុមគ្រួសាររបស់យើងជាជនអន្តោប្រវេសន៍។ នៅក្នុងគេហទំព័ររបស់យើង ដែលមានជា **lbschools.net/solidarity** គឺមានការផ្តល់ព័ត៌មាន និងធនធានចាំបាច់ជូនសិស្ស និងក្រុមគ្រួសារអំពីសិទ្ធិការពារដោយច្បាប់ និងដៃគូរអាចទុកចិត្តបាន ដើម្បីសម្រួលមកលើការធ្វើដំណើរក្នុងកម្មវិធីអប់រំរបស់ពួកគេ។ យើងខ្ញុំសូមលើកទឹកចិត្តអ្នកឱ្យបើកមើលក្នុងគេហទំព័រ ដើម្បីទទួលបានព័ត៌មាន ធនធាន និងសេចក្តីប្រកាសថ្មីៗ។

## សុខភាព និងសុខុមាលភាពនៅឯផ្ទះ

មាតាបិតាត្រូវបានទទួលការរំលឹកឱ្យឃ្លាំមើលរោគសញ្ញាដូចតទៅ ដែលអាចកើតមានឡើងបាន មុននឹងបញ្ជូនសិស្សទៅសាលា។



- គ្រុនដែលមានកំដៅខ្លួន 100.4 អង្សា ឬលើស
- ក្អក ឈឺបំពង់ក តឹងច្រមុះ ឬហៀរសំបោរ
- ស្ទើរដង្ហើម ឬពិបាកដកដង្ហើម
- បាត់បង់រសជាតិ ឬការធំ ក្លិនក្នុងពេលថ្មីៗ
- ចង្អោរ ក្អួត ឬចុករាគ

សម្រាកនៅផ្ទះ៖ បើមិនស្រួលខ្លួន និងទាក់ទងប្រាប់សាលានៃសិស្សរបស់អ្នក។



## គោលការណ៍ច្បាប់របស់មន្ទីរអប់រំ LBUSD អំពីការប្រើទូរស័ព្ទដៃ

សេចក្តីរំលឹកអំពីគោលការណ៍ច្បាប់ ដែលប៉ះពាល់ដល់ការប្រើទូរស័ព្ទដៃ និងឧបករណ៍ផ្សេងៗរបស់សិស្ស៖ ក្នុងឆ្នាំសិក្សាឆ្នាំនេះ មន្ទីរអប់រំ LBUSD នឹងបន្តធ្វើជាដដែលក្នុងការប្រព្រឹត្តតាម**គោលការណ៍ច្បាប់ លេខ 5131.8៖ ការកាត់បន្ថយភាពរំខាន និងការគាំទ្រសុខុមាលភាព** ដើម្បីគាំទ្រការសិក្សាការចូលរួម និងសុខុមាលភាពរបស់សិស្ស។ សូមអានបន្ថែមនៅក្នុងគេហទំព័រ **lbschools.net/phonepolicy** ដើម្បីយល់ដឹងកាន់តែច្បាស់លាស់អំពីគោលការណ៍ច្បាប់របស់ក្រុមប្រឹក្សាភិបាលអប់រំ និងទទួលបាននូវព័ត៌មាន និងធនធានថ្មីៗ។

## មជ្ឈមណ្ឌលឧត្តមភាពសំរាប់សិស្ស ខ្មៅ

មន្ទីរអប់រំ LBUSD តាំងការប្តេជ្ញាចិត្ត ដើម្បីបង្កើនភាពជោគជ័យរបស់សិស្ស តាមរយៈការអះអាងទទួលស្គាល់វប្បធម៌ ការផ្តួចផ្តើមគោលគំនិត និងភាពជាដៃគូ។ មជ្ឈមណ្ឌលឧត្តមភាពសំរាប់សិស្ស ខ្មៅ គឺជាកន្លែងដ៏សកម្មមួយដែលសិស្ស និងក្រុមគ្រួសារអាចទទួលបាននូវការបង្កើនសមត្ថភាព ការគាំទ្រ និងការអបអរ។ វាជាកន្លែងផ្តល់ធនធានផ្នែកការសិក្សា ការបំប៉នផ្នែកវប្បធម៌ និងការស្វាគមន៍រាក់ទាក់គ្នា ដើម្បីទទួលបាននូវភាពល្អលាស់។ មានការប្រឹងប្រែងក្នុងទូទាំងមន្ទីរអប់រំនៅទូទាំងឆ្នាំសិក្សា ដើម្បីផ្តល់ជាកម្មវិធីផ្សេងៗ ដូចជា៖ Sankofa ការអប់រំណែនាំ និងការបើកឱកាសសំរាប់ក្រុមគ្រួសារចូលរួម ដើម្បីគាំទ្រផ្នែកការសិក្សា ការធ្វើទំនាក់ទំនង និងសុខភាពផ្នែកអារម្មណ៍របស់សិស្ស។

នៅតាមអនុវិទ្យាល័យ និងវិទ្យាល័យ គឺសិស្សអាចចូលរួមនៅក្នុងក្រុមជាច្រើនបាន ដូចជា៖ សហភាពសិស្ស ខ្មៅ (BSU) បញ្ញាវន្តសិស្ស ខ្មៅ និងសង្គមអក្ខរកម្មសិស្ស ខ្មៅ ដែលត្រូវបានបង្កើតឡើង ដើម្បីបណ្តុះបណ្តាលភាពដឹកនាំ មោទនភាពវប្បធម៌ និងការត្រៀមខ្លួនចូលរៀននៅមហាវិទ្យាល័យ។ ដើម្បីរៀនយល់កាន់តែច្បាស់ សូមពិនិត្យនៅតាមគេហទំព័រ lbschools.net/BSAI ឬ ធ្វើការទាក់ទងតាមលេខទូរស័ព្ទ (562) 366-2245។

Black Student Achievement Initiative LBUSD




## ទស្សនវិស័យ 2025 និង ផែនការវិធីសាស្រ្ត

បេសកកម្មរបស់យើង គឺជួយត្រៀមសិស្សគ្រប់រូបឱ្យបានទទួលភាពជោគជ័យទៅថ្ងៃមុខ ដោយផ្តល់ជាការដោះស្រាយចម្លើយយ៉ាងហ្មត់ចត់ និងបទពិសោធន៍ផ្នែកសិក្សាដែលស្របតាមរយៈវប្បធម៌ រួមទាំងកាត់ផ្តាច់នូវបញ្ហារាំងស្ទះផ្សេងៗ ដើម្បីធ្វើឱ្យសិស្សបានទទួលភាពជោគជ័យនៅក្នុងប្រព័ន្ធសាលាមួយដែលមានសមធម៌ ការបញ្ជាក់អះអាង និងការគិតគូរដែលឆ្ពោះទៅរកអនាគតកាល។

## ផែនការវិធីសាស្រ្តសំរាប់ឆ្នាំ 2024-2029

ក្នុងការកសាងអនាគតកាន់តែប្រសើររួមគ្នា ដែលមាននៅក្នុងផែនការវិធិសាស្រ្ត 2024-2029 របស់យើង គឺចាប់ផ្តើមឡើងនៅវគ្គដំបូងក្នុងចំណោមវគ្គបន្តបន្ទាប់គ្នាជាច្រើនឆ្នាំទៅមុខ និងរាយបង្ហាញអំពីវិធានការដែលយើងនឹងចាត់ចែងធ្វើ ដើម្បីឆ្ពោះដល់គោលដៅពិតប្រាកដនៃទស្សនវិស័យរបស់យើង។ វាមានជាបួនប្រធានបទដែលរួមគ្នា គឺនឹងបង្កើតជាមូលដ្ឋានគ្រឹះសំរាប់ការធ្វើឱ្យបានដូចទស្សនវិស័យរបស់យើង។ ប្រធានបទទាំងអស់នេះ គឺមានភាពចាំបាច់ណាស់ ដើម្បីជួយយើងឱ្យបានឆ្ពោះដល់ទស្សនវិស័យ 2035 ជាពិសេស រូបភាពរបស់អ្នកបញ្ចប់ការសិក្សា សំរាប់សិស្សទាំងអស់នៅក្នុងមន្ទីរអប់រំ LBUSD។

- ប្រធានបទ 1៖ គុណភាពខ្ពស់ផ្នែកការសិក្សាសំរាប់សិស្ស
- ប្រធានបទ 2៖ មន្ទីរអប់រំដែលផ្តល់សមធម៌ និងសេរីភាព
- ប្រធានបទ 3៖ ភាពដៃគូជាមួយសហគមន៍
- ប្រធានបទ 4៖ ការបណ្តុះបណ្តាលភាពកែប្រែ ស្របដោយនិន្តរភាព

ដើម្បីរៀនយល់កាន់តែច្បាស់អំពីមធ្យោបាយដែលយើងគិតមើលឡើងវិញអំពីកម្មវិធីអប់រំ សូមមេត្តាអាននៅតាម **lbschools.net/stategicplan**។